# ការអនុវត្តន៍ល្អ

## ផ្តល់ការគាំទ្រដល់ម្តាយដែលធ្វើការ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ប្រទេសភាគច្រើនមានច្បាប់ដែលចែងជាពិសេសអំពីម្តាយដែលធ្វើការ ។ ច្បាប់កម្ពុជាតម្រូវឱ្យនិយោជកដែលជួលស្ត្រីធ្វើការងារលើសពី ១០០ នាក់ឡើងទៅ ឱ្យបង្កើត និងតំណើរការបន្ទប់បំបៅដោះកូន និងកន្លែងថែរទាំកុមារ ។ ការអនុវត្តន៍តាមច្បាប់ទាំងនេះ ធានាឱ្យមានទឹកចិត្តខ្ពស់ក្នុងចំណោមកម្មករ និងកេរ្តិ៍ឈ្មោះមួយដ៏ល្អក្នុងចំណោមអ្នកបញ្ជាទិញ ។ ការផ្គត់ផ្គង់បន្ទប់បំបៅដោះកូន និងកន្លែងថែរទាំកុមារ ផ្តល់នូវបរិយាកាសជាវិជ្ជមានមួយសំរាប់ម្តាយទាំងឡាយដែលនឹងត្រលប់ចូលមកធ្វើការងារវិញ ។

### ការអនុវត្តន៍ល្អសំរាប់ការរៀបចំចូលដ្ឋានសំភារៈសំរាប់បំបៅដោះកូន និងថែរទាំកុមារ

- ត្រូវផ្តល់ការឈប់សំរាកលំហែរមាតុភាពមានប្រាក់ឈ្នួលចំនួន ៩០ ថ្ងៃ (បីខែ) ដល់ម្តាយដែលធ្វើការ និងដែលមានអតីតភាពការងារយ៉ាងហោចណាស់មួយឆ្នាំ (រូបភាពទី ១) ។
- អនុញ្ញាតឱ្យបុគ្គលិកដែលត្រលប់មកពីការឈប់សំរាកលំហែរមាតុភាពធ្វើតែការងារស្រាល១នៅអំឡុងពេល២ខែតំបូងពេលគេមកធ្វើការវិញ ។
- ត្រូវធានាថាគ្រប់កម្មករមានផ្ទៃពោះទទួលបានស្ថេរភាពការងារពេញលេញ ។
- ចូរផ្តល់ដល់ស្ត្រីដែលបំបៅកូនដោយទឹកដោះខ្លួននូវការឈប់សំរាក ១ ម៉ោងមានប្រាក់ឈ្នួលដើម្បីបំបៅដោះកូនរៀងរាល់ថ្ងៃក្នុងអំឡុងមួយឆ្នាំតំបូងនៃជីវិតរបស់ទារក ។ ម៉ោងឈប់សំរាកនេះអាចមានភាពបត់បែនបាន (រូបភាពទី ២) ។
- ចូរផ្តល់ទីកន្លែងបំបៅដោះកូន និងកន្លែងថែទាំកុមារនៅនឹងកន្លែងការងារ (រូបភាពទី ៣) ។
- ចូរលើកទឹកចិត្តកម្មកររួមការងារ និងអ្នកគ្រប់គ្រងឱ្យមានអាក្បកិរិយាទទួលស្គាល់ និងគាំទ្រដល់ការបំបៅដោះកូន (រូបភាពទី ២) ។



រូបភាពទី១



រូបភាព:UNICEF

រូបភាពទី២



រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ ម្តាយដែលបំបៅកូននឹងទឹកដោះតែមួយមុខគត់សំរាប់អំឡុង ៦ ខែតំបូងនៃជីវិតរបស់ទារក នឹងមានទារកដែលមានសុខភាពកាន់តែល្អប្រសើរ និងរីករាយ
- ✓ ម្តាយដែលមានទារកមានសុខភាពល្អមិនសូវមានការព្រួយបារម្ភ និងកាន់តែមានផលិតភាពការងារខ្ពស់
- ✓ ម្តាយដែលបំបៅដោះទារកតែងតែមានភាពអវត្តមានពីការងារក្នុងកំរិតតិចតួច
- ✓ មានការគាំទ្រល្អដល់ម្តាយដែលធ្វើការងារ នឹងធ្វើឱ្យគេត្រឡប់មកធ្វើការងារវិញក្រោយពីការសំរាកលំហែរមាតុភាព ។ ហេតុផលនេះនឹងអាចឱ្យនិយោជករក្សាទុកបាននូវកម្មករដែលមានការបណ្តុះបណ្តាល មានបទពិសោធន៍ និងមានចំណង់ការងារ និងជាកម្មករមានការស្មោះស្ម័គ្រចំពោះនិយោជក

### តាមរបៀបណា:

- ✓ ត្រូវផ្តល់ទីកន្លែងដល់ស្ត្រីជាម្តាយនៃទារកឱ្យបំបៅដោះកូននៅកន្លែងការងារ ។ ត្រូវប្រើប្រាស់បន្ទប់ទំនេរដែលស្ងាត់ និងឯកជន
- ✓ រក្សាបរិយាកាសនៃបន្ទប់បំបៅដោះកូនឱ្យមានភាពស្អាតបាត និងមានសុវត្ថិភាព
- ✓ ត្រូវមានការព្រមព្រៀងជាមួយនឹងកម្មករនិយោជិតលើកាលវិភាគឈប់សំរាកបំបៅដោះកូនឱ្យមានភាពច្បាស់លាស់ជាមុន

### តំលៃ:

**$ - $$**

$ តំលៃទាប

$$ តំលៃមធ្យម

$$$ តំលៃខ្ពស់

អង្គការ
ពលកម្ម
អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយ:អ៊ីម៉េល betterfactories@ilo.org